ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តបាត់ដំបង

លេខ÷ .....១៩៤៣......... សហវ.បប

# របាយការណ៍ ស្តីពី
# វឌ្ឍនភាព នៃការអនុវត្តការងាររបស់
# មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបងប្រចាំ
# ឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្ត

ការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ

ថ្ងៃ ព្រហស្បតិ៍ ០៧ កើត ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

បាត់ដំបង, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០២៥

## មាតិកា


១.សេចក្តីផ្តើម ........ 3

២. វឌ្ឍនភាពនៃការអនុវត្តការងារប្រចាំ ឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្ត ........ 3

២.១.ការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ( គិតត្រឹមថ្ងៃ ចន្ទ ទី ១៧ ខែ វិច្ឆិកា ២០២៥)

ក.ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ........ 3

ខ. ការងារចុះប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ........ 4

គ. កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណ: ........ 5

ឃ.ការងារគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ........ 5

ង.ការងារសន្តិសុខ ៖ ........ 5

២.២.ការងារហិរញ្ញវត្ថុ ( ការិ.ថវិកាមន្ទីរជំនាញ និងការិ.ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ) គិតត្រឹម ថ្ងៃ ចន្ទ ទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២៥ ........ 5

ក.ការអនុវត្តចំណូលមិនមែនសារពើពន្ធ( លើកលែងចំណូលពន្ធដារ និងគយ រដ្ឋាករ គិតត្រឹមថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២៥)៖ ........ 5

ខ.ការអនុវត្តចំណាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ( គិតត្រឹមថ្ងៃ ចន្ទ ទី ១៣ ខែ វិច្ឆិកា ២០២៥)៖ ........ 7

គ. ចំណាយថវិកាថ្នាក់ជាតិ ( មន្ទីរជំនាញ): ( គិតត្រឹម ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២៥ ) ........ 8

ឃ. ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ( សាលាខេត្ត ក្រុង/ ស្រុក) : ( គិតត្រឹមថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២៥) ........ 8

២.៣ ការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ( គិតត្រឹមថ្ងៃទី ១៧ ខែ វិច្ឆិកា ២០២៥) ........ 8

២.៤ ការិយាល័យលទ្ធកម្មសាធារណ:( គិតត្រឹមថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០២៥) ........ 9

៤-ទិសដៅបន្តអនុវត្តក្នុងឆ្នាំ២០២៦ ........ 11

៥-សំណូមពរ ........ 13

៦-សេចក្តីសន្និដ្ឋាន ........ 13

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តបាត់ដំបង

# សូមគោរពជូន

## ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**តាមរយៈ:ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ:** របាយការណ៍ស្តីពីវឌ្ឍនភាព នៃការអនុវត្តការងាររបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបងប្រចាំឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្ត

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដោយសង្ខេបនូវវឌ្ឍនភាពនៃការអនុវត្តការងាររបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបងសម្រេចបាន ក្នុងឆ្នាំ២០២៥ មានដូចខាងក្រោម:

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបាត់ដំបងជាអង្គភាពរដ្ឋបាលសេដ្ឋកិច្ចបំពេញមុខងារ ជាតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើការងារសម្របសម្រួលអង្គភាពថ្នាក់មូលដ្ឋានរបស់ក្រសួង អនុវត្តភារកិច្ចគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានការិយាល័យចំណុះចំនួន០៥អនុវត្តសកម្មភាពតាមវិស័យសម្រេចជាលទ្ធផលរួមដូចខាងក្រោម ៖

### ១.សេចក្តីផ្តើម

- មានមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកជាប់កិច្ចសន្យាសរុបចំនួន ៣៨នាក់ ស្ត្រី ១៦នាក់ ដឹកនាំ ដោយប្រធាន ០១នាក់ ទទួលបន្ទុកក្តាប់រួម អនុប្រធានមន្ទីរ ០២នាក់ និងប្រធានការិយាល័យ ០២នាក់ ស្ត្រី ០១នាក់។ ក្នុងនោះអនុប្រធានការិយាល័យមានចំនួន ១០នាក់ ស្រី ចំនួន ០៦នាក់។ មន្ត្រីរាជការស៊ីវិល សរុប ៣២រូប ស្រី ១៣រូប និងមន្ត្រីជាប់កិច្ចសន្យា ចំនួន ០៦រូប ស្រី ០៣នាក់ និងបុគ្គលិកកិច្ចសន្យា ចំនួន១រូប។

### ២. វឌ្ឍនភាពនៃការអនុវត្តការងារប្រចាំ ឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្ត

### ២.១.ការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ (គិតត្រឹមថ្ងៃ ចន្ទ ទី ១៧ ខែ វិច្ឆិកា ២០២៥)

### ក.ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ

- អាណត្តិថ្នាក់ក្រោមជាតិចំនួន ÷ 564 ច្បាប់ កើនចំនួន 39 ច្បាប់ ធៀបនឹងឆ្នាំ២០២៤ ចំនួន 525 ច្បាប់

- **ថ្នាក់ជាតិចំនួន** ÷ 971 ច្បាប់ ថយចំនួន -1,801 ច្បាប់ ធៀបនឹងឆ្នាំ២០២៤ ចំនួន 2,772 ច្បាប់
- **លិខិតចូលចំនួន** ÷1,241 ថយចំនួន -1,01 ច្បាប់ ធៀបនឹងឆ្នាំ២០២៤ ចំនួន 2,255 ច្បាប់
- **លិខិតចេញចំនួន** ÷ 2,848 ច្បាប់ កើនចំនួន 76 ច្បាប់ ធៀបនឹងឆ្នាំ២០២៤ ចំនួន 2,772 ច្បាប់
- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការបានចូលរួម កិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងសកម្មភាពសង្គមនានា នៅមន្ទីរ, ក្នុង និងក្រៅខេត្ត ចំនួន 380 លើក (ក្នុងខេត្តគ្មានបេសកកម្ម 230 បេសកកម្មក្នុងខេត្ត 30 លើក បេសកកម្មឆ្លងខេត្ត 120 លើក) កើនចំនួន 55 ច្បាប់ ធៀបនឹងឆ្នាំ២០២៤ ចំនួន 325 ច្បាប់។
- បានរៀបចំកិច្ចផ្សាល់ និងអនឡាញ នៅសាលប្រជុំមន្ទីរ ចំនួន 90 លើក កើន/ថយចំនួន ...ច្បាប់ ធៀបនឹងឆ្នាំ២០២៤ ចំនួន 120ច្បាប់។
- ការងាររៀបចំលិខិតអញ្ជើញ,លិខិតចេញ, ឯកសារទូទាត់ថវិកាបេសកកម្ម (មករា-កញ្ញា),ចំណាយផ្សេងៗះបៀវត្សខែមក-តុលា,អត្តីសនីខែមករា-កញ្ញា,សលាកបត្រមន្ត្រីរាជការ,របាយការណ៍ចំណាយប្រចាំខែ,ពាក់កណ្តាលឆ្នាំ,៩ខែ,របាយការណ៍វឌ្ឍនភាពប្រចាំខែ,របាយការណ៍អនុវត្តលទ្ធកម្ម, កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២៦-២០២៨ និងសំណើសុំរបស់មន្ទីរនានា ចំនួន 300 ច្បាប់ កើនចំនួន 60 ច្បាប់ ធៀបនឹងឆ្នាំ២០២៤ ចំនួន 360ច្បាប់។
- បានចូលរួមធ្វើពលកម្មសម្អាតបរិវេណជុំវិញមន្ទីរ និងគោរពទង់ជាតិប្រចាំសប្តាហ៍ ក្នុងខែមករា-តុលា ឆ្នាំ២០២៥
- មានមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកជាប់កិច្ចសន្យាសរុបចំនួន ៣៨នាក់ ស្ត្រី ១៦នាក់ ដឹកនាំ ដោយប្រធាន ០១នាក់ ទទួលបន្ទុកក្តាប់រួម អនុប្រធានមន្ទីរ ០២នាក់ និងប្រធានការិយាល័យ ០២នាក់ ស្ត្រី ០១នាក់។ ក្នុងនោះអនុប្រធានការិយាល័យមានចំនួន ១០នាក់ ស្រី ចំនួន ០៦នាក់។ មន្ត្រីរាជការស៊ីវិល សរុប ៣២រូប ស្រី ១៣រូប និងមន្ត្រីជាប់កិច្ចសន្យា ចំនួន ០៦រូប ស្រី ០៣នាក់ និងបុគ្គលិកកិច្ចសន្យា ចំនួន១រូប។
- ការងារបញ្ចូលការបញ្ជាទិញកិច្ចលទ្ធកម្មរបស់មន្ទីរជំនាញចំនួន២៧៥ បូកយោង ២៧៥ មានកំណើនចំនួន ០០គម្រោង ធៀបនឹងខែ កញ្ញា បូកយោងចំនួ ២៧៥ គម្រោង ។
- បានចូលរួមធ្វើពលកម្មសម្អាតបរិវេណជុំវិញមន្ទីរ និងគោរពទង់ជាតិប្រចាំសប្តាហ៍ ក្នុងខែមករា-វិច្ឆិកា ឆ្នាំ២០២៥
- **ទិសដៅបន្ត៖**
- ត្រៀមទិន្នន័យ សរសេរវិភាគ SWOT ឆ្នាំ២០២៦។ អានឯកសារយោងទី ៥ និងបញ្ចូលដល់ទំព័រ ៣០០/៣៥៩ទំព័រ ។
- កំពុងតម្រូវទិន្នន័យព័ត៌មានសេដ្ឋកិច្ចនិងសង្គមខេត្តបាត់ដំបងឆ្នាំ២០២៥។ទំព័រ១១/១៥។ ស្មើនឹង ៧៣%នៃផែនការសកម្មភាព
- កំពុងរៀបចំឯកសារពាក់ព័ន្ធដើម្បីរៀបចំកិច្ចប្រជុំត្រួតពិនិត្យ និងផ្តល់យោបល់លើ ឯកសារវិភាគ SWOT ខេត្តបាត់ដំបងឆ្នាំ២០២៥ និងប្រមូលធាតុចូល ពីគ្រប់មន្ទីរ រដ្ឋបាលក្រុង ស្រុកពាក់ព័ន្ធ ដើម្បីរៀបចំការវិភាគ SWOT ខេត្តបាត់ដំបងឆ្នាំ២០២៦។
- កំពុងប្រមូល និងបូកសរុប របាយការណ៍វឌ្ឍនភាប្រចាំខែ មករា ឆ្នាំ២០២៦ របស់មន្ទីរ។

## ខ. ការងារចុះប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ

- ការងារបញ្ចូលការបញ្ជាទិញកិច្ចលទ្ធកម្មរបស់មន្ទីរជំនាញចំនួន ២៧៥ បូកយោង ២៧៥ មានថយចុះចំនួន ០២ គម្រោង ធៀបនឹងបូកយោងឆ្នាំ ២០២៥ ចំនួន ២៧៥ គម្រោង ។

- មន្ទីរមានកុំព្យូទ័រប្រព័ន្ធ FMIS សរុបចំនួន ១៤គ្រឿង និងមានអ្នកអនុម័ត និងអ្នកប្រើប្រាស់ប្រព័ន្ធសរុបចំនួន ១៩នាក់ ស្រី ០៩នាក់។ មន្ទីរបានជម្រះកុំព្យូទ័រប្រព័ន្ធ FMIS ចំនួន ០៩គ្រឿង និងទទួលបានកុំព្យូទ័រប្រព័ន្ធ FMIS ថ្មី ចំនួន ០៩គ្រឿង សរុបចំនួន ១៤គ្រឿង ដដែល។
- ការងារបញ្ចូលមុខងារលទ្ធកម្មពេញលេញ (PR)ក្នុងប្រព័ន្ធ FMIS៖ ផែនការលទ្ធកម្មឆ្នាំ២០២៥ មានចំនួន១៤គម្រោង។ បានទទួលការអនុម័តរបស់អគ្គលទ្ធកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- ការងារបញ្ចូលផែនការថវិកា (BSP) និងផែនការចំណូលចំណាយថវិកាកម្មវិធីឆ្នាំ២០២៦៖ បានកែតម្រូវទិន្នន័យក្នុងប្រព័ន្ធ និងបានទទួលការអនុម័តរបស់ថ្នាក់ដឹកនាំរួចរាល់។ បន្តកែតម្រូវទិន្នន័យផ្អែកតាមសៀវភៅថវិកា ២០២៦។
- **ការងារត្រួតពិនិត្យ និងបញ្ចូលរបាយការណ៍ចំណាយចរន្តតាមប្រព័ន្ធ Online របស់សាកលវិទ្យាល័យជាតិបាត់ដំបង (ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល)៖** កំពុងបញ្ចូលអាណត្តិចំណាយក្នុងខែ វិច្ឆិកា ២០២៥ របស់សាកលវិទ្យាល័យជាតិបាត់ដំបង។

**គ. កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ**

- បានធ្វើមត្តទេសខេត្តបាត់ដំបងឆ្នាំ២០២៥ ដល់ទំព័រទី៤២។
- បានរៀបចំរបាយការណ៍សមិទ្ធកម្ម និងរបាយការណ៍អនុវត្តហិរញ្ញវត្ថុកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈត្រីមាសទី១-ឆមាសទី៤ ឆ្នាំ២០២៥ និង ឆ្នាំ២០២៥ របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង
- បានធ្វើបច្ចុប្បន្នភាពទិន្នន័យវិភាគភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែងក្នុងកិច្ចអភិវឌ្ឍន៍ខេត្តបាត់ដំបងឆ្នាំ២០២៥ និងបានធ្វើsoft ជូនក្រុមការងារកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ឃ.ការងារគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម**

- បានផុសរូបភាព និងវីដេអូសកម្មភាពរបស់ថ្នាក់ដឹកនាំ និងមន្ត្រីមន្ទីរ ក្នុងហ្វេសប៊ុកផេករបស់មន្ទីរ គេហទំព័រមន្ទីរនិងគ្រុបតេឡេក្រាមក្រុមការងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បានផុស និងចែករំលែកនូវព័ត៌មានថ្មីៗតាមការណែនាំរបស់រដ្ឋបាលខេត្ត។
- **ការងារហ្វេសប៊ុកផេកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្មីទី៣៖** គិតត្រឹម សប្តាហ៍ទី៤ ខែ វិច្ឆិកា ២០២៥ មានអ្នកតាមដានផេកចំនួន ៨,៦K នាក់ (កើន 8,462 នាក់ ក្នុង១ខែ), កំពុងតាមដាន ចំនួន 59នាក់ (កើន 06នាក់ ក្នុង ១ខែ)។
- **គណៈកម្មាធិការគណបក្សមូលដ្ឋាន មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង** ៖គិតត្រឹម សប្តាហ៍ទី4 ខែ វិច្ឆិកា ២០២៥ មានអ្នកតាមដានផេកចំនួន ០៩ នាក់ (កើន០០ នាក់ ក្នុង១ខែ), កំពុងតាមដាន ចំនួន ៥១នាក់ (ថយ ០១នាក់ ក្នុង ១ខែ)។

**ង.ការងារសន្តិសុខ ៖**

- ភ្ញៀវមកទំនាក់ទំនងពេលព្រឹកចំនួន 1,151 នាក់ ពេលល្ងាចចំនួន 892 នាក់ សរុបចំនួន 2,043នាក់។

**ច.ការងារបណ្ណសារ និងវត្ថុមាន**

- បានប្រមូលឯកសារចេញរបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាប់ពីឆ្នាំ ២០២៣ចុះ ជូន មន្ត្រីបង្គោលទទួលបន្ទុកការងារ បណ្ណសារមន្ទីរ បាន ៣៥ ច្បាប់ បូកយោង ៧៧ ច្បាប់។

**១. ឯកសារតម្កល់÷** ក.បានរៀបចំឯកសារ ជានិច្ចកាល(ច) និងឯកសារបណ្តោះអាសន្ន (ប)ជាប្រចាំ។

បានរៀបចំឯកសារ ជានិច្ចកាល បណ្តោះអាសន្ន ទុកបញ្ចូលក្នុងប្រព័ន្ធ

**២.ឯកសារបំផ្លាញ** ÷ឯកសារតូចតាច (ឯកសារហួសសុពលភាពប្រើប្រាស់)។

**៣-ការងារបញ្ជីវត្ថុមាន-អចលនវត្ថុមាន** ÷បានរៀបចំរបាយការណ៍បញ្ជីវត្ថុមាន-អវត្តមានប្រចាំសប្តាហ៍ និងប្រចាំ មករា-វិច្ឆិកា ២០២៥

**២.២.ការងារហិរញ្ញវត្ថុ (ការិ.ថវិកាមន្ទីរជំនាញ និងការិ.ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ) គិតត្រឹម ថ្ងៃ ចន្ទ ទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២៥**

**ក.ការអនុវត្តចំណូលមិនមែនសារពើពន្ធ(លើកលែងចំណូលពន្ធដារ និងគយ រដ្ឋាករ គិតត្រឹម ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២៥)៖**

- ចំណូលមិនមែនសារពើពន្ធក្នុងឆ្នាំ២០២៥(ថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិលើកលែងចំណូលពន្ធដារ គយ រដ្ឋាករ)បូកយោង (មករា-វិច្ឆិកា) ចំនួន **302,185,625,991**រៀល ស្មើនឹង **89.83%** នៃច្បាប់ហិរញ្ញ វត្ថុកែតម្រូវ ចំនួន 336,387,590,000រៀល ។
- ថវិកាថ្នាក់ជាតិ(មន្ទីរជំនាញ) ក្នុងឆ្នាំ២០២៥បូកយោង (មករា-វិច្ឆិកា)ចំនួន **4,683,525,403** រៀល ស្មើនឹង **52.61%** (ហាសិបពីរក្បៀសហុកសិបមួយភាគរយ) ធៀបនឹងផែនការឆ្នាំ២០២៥ ចំនួន **8,901,900,000**រៀល (ប្រាំបីពាន់ ប្រាំបួនរយមួយលាន ប្រាំបួនរយពាន់រៀលគត់)។
- ថវិកាថ្នាក់ក្រោមជាតិ (សាលាខេត្ត,មន្ទីរសុខាភិបាល, ក្រុង-ស្រុក,សាលារៀនក្រុង-ស្រុក)ក្នុងឆ្នាំ២០២៥ សរុបចំនួន០រៀល បូកយោង (មករា-វិច្ឆិកា)ចំនួន **297,502,100,588**រៀល ស្មើនឹង **90.84%** ធៀបនឹងផែនការឆ្នាំ ២០២៥ ចំនួន **327,485,690,000**រៀល ។

ឯកត្តា:រៀល

| ប្រភេទ,ចំណូល ខែវិច្ឆិកា ២០២៥ | ច្បាប់ហិរញ្ញវត្ថុកែតម្រូវ ឆ្នាំ២០២៥(៛) | %ធៀបនឹងច្បាប់ហិរញ្ញវត្ថុកែតម្រូវ ឆ្នាំ២០២៥ | បូកយោងចំណូលខែមុន មករា-តុលា ២០២៥(៛) | ចំណូលជាក់ស្តែង ខែវិច្ឆិកា ២០២៥ (៛) | បូកយោងចំណូល ខែមករា-វិច្ឆិកា ២០២៥ (៛) | **បូកយោងចំណូល ខែមករា-វិច្ឆិកា ២០២៤** | **%ធៀបនឹងផែនការ ឆ្នាំ២០២៤** |
|---|---|---|---|---|---|---|---|
| **មិនមែនសារពើពន្ធសរុប** | **336,387,590,000** | 89.83% | 302,185,625,991 | 0 | **302,185,625,991** | **៣១៨,៩២៦,៦០៩,២៦៣** | **៩៧.០៩%** |
| **ថ្នាក់ជាតិ** | **8,901,900,000** | **52.61%** | **4,683,525,403** | **0** | **4,683,525,403** | ៦,០៨៤,០៧២,៨៦៣ | ៥៩.២៩% |
| **ថ្នាក់ក្រោមជាតិ** | **327,485,690,000** | **90.84%** | **297,502,100,588** | **0** | **297,502,100,588** | ៣១២,៨៤២,៥៣៦,៤០០ | ៩៨.៣២% |
| សាលាខេត្ត | 49,902,000,000 | 60.34% | 30,111,503,612 | 0 | 30,111,503,612 | | |
| មន្ទីរសុខាភិបាល | 65,179,600,000 | 100.00% | 65,179,600,000 | 0 | 65,179,600,000 | | |
| ក្រុងស្រុក | 45,182,990,000 | 77.44% | 34,989,896,976 | 0 | 34,989,896,976 | | |
| សាលារៀន(ក្រុង-ស្រុក) | 167,221,100,000 | 100.00% | 167,221,100,000 | 0 | 167,221,100,000 | | |

**ខ.ការអនុវត្តចំណាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ( គិតត្រឹមថ្ងៃ ចន្ទ ទី ១៣ ខែ វិច្ឆិកា ២០២៥ )៖**

- ចំណាយក្នុងឆ្នាំ២០២៥ បូកយោង(មករា-វិច្ឆិកា)ចំនួន **383,233,127,290**រៀលស្មើនឹង **77.75%** ច្បាប់ហិរញ្ញកែតម្រូវចំនួន **492,910,670,000** រៀល។
- ថវិកាថ្នាក់ជាតិ(មន្ទីរជំនាញ)ចំណាយក្នុង ឆ្នាំ២០២៥ បូកយោង(មករា-វិច្ឆិកា) ចំនួន **139,022,565,074**រៀល ស្មើនឹង **88.81%** ធៀបនឹងច្បាប់ហិរញ្ញវត្ថុកែតម្រូវឆ្នាំ២០២៥ចំនួន **156,530,780,000**រៀល
- ថវិកាថ្នាក់ក្រោមជាតិ(សាលាខេត្ត,មន្ទីរសុខាភិបាល,ក្រុង-ស្រុក,សាលារៀនក្រុង-ស្រុក) ចំណាយក្នុង ឆ្នាំ ២០២៥ បូកយោង (មករា-វិច្ឆិកា) ចំនួន **244,210,562,216**រៀល ស្មើនឹង **72.60%** នៃច្បាប់ហិរញ្ញ វត្ថុកែតម្រូវ ចំនួន **336,379,890,000**រៀល ។

ឯកត្តៈរៀល

| ប្រភេទចំណាយ | ច្បាប់ហិរញ្ញវត្ថុកែតម្រូវឆ្នាំ ២០២៥ (៛) | %ធៀបនឹងច្បាប់ហិរញ្ញវត្ថុកែតម្រូវ | បូកយោងចំណាយ (ខែមករា-តុលា) ២០២៥ | ចំណាយជាក់ស្តែងខែវិច្ឆិកា ឆ្នាំ២០២៥ (៛) | បូកយោងចំណាយខែមករា-វិច្ឆិកា ឆ្នាំ២០២៥(៛) | **បូកយោងចំណាយ ខែមករា-វិច្ឆិកា ២០២៤** | **%ធៀបនឹងផែនការ ឆ្នាំ២០២៤** |
|---|---|---|---|---|---|---|---|
| ថ្នាក់ជាតិនិងក្រោមជាតិសរុប | 492,910,670,000 | 77.75% | 367,701,403,724 | 15,531,723,566 | 383,233,127,290 | ៣៨២,១៤២,៩៤៣,៩៤៧ | ៧៨.៧៥% |
| ថ្នាក់ជាតិ | 156,530,780,000 | 88.81% | 130,593,710,928 | 8,428,854,146 | 139,022,565,074 | ១៣៥,០០១,៤៣៦,៣៨២ | ៨៥.២៦% |
| ថ្នាក់ក្រោមជាតិ | 336,379,890,000 | 72.60% | 237,107,692,796 | 7,102,869,420 | 244,210,562,216 | ២៤៧,១៤១,៥០៧,៥៦៥ | ៧៥.៦១% |
| សាលាខេត្ត | 57,341,000,000 | 58.15% | 29,575,202,860 | 3,768,398,640 | 33,343,601,500 | | |
| មន្ទីរសុខាភិបាល | 65,179,600,000 | 66.71% | 40,145,010,070 | 3,334,470,780 | 43,479,480,850 | | |
| ក្រុង ស្រុក | 46,638,190,000 | 70.94% | 33,084,034,985 | 0 | 33,084,034,985 | | |
| សាលារៀន | 167,221,100 | 80.31% | 134,303,444, | 0 | 134,303,444, | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ,000 | | 881 | | 881 | | |

**គ. ចំណាយថវិកាថ្នាក់ជាតិ (មន្ទីរជំនាញ): (គិតត្រឹម ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២៥ )**

- បានពិនិត្យ និងផ្តល់ទិដ្ឋាការលើការចំណាយប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ប្រចាំខែមករា- វិច្ឆិកា ឆ្នាំ២០២៥ ជូនមន្ទីរជំនាញទាំង ២៥អង្គភាព
- **បានពិនិត្យ និងផ្តល់ទិដ្ឋាការលើសំណើធានាចំណាយ(កិច្ចលទ្ធកម្ម)** ប្រចាំខែមករា-វិច្ឆិកា ឆ្នាំ២០២៥
- **បានពិនិត្យ និងផ្តល់ទិដ្ឋាការលើការចំណាយ វេជ្ជទេយ្យបុរេប្រទានជុំទី ០១-០៤**ប្រចាំខែមករា- វិច្ឆិកា ឆ្នាំ២០២៥
- **ការងារប្រព័ន្ធ FMIS ប្រចាំខែ វិច្ឆិកា ឆ្នាំ២០២៥៖**
- **មុខងារគណនីត្រូវសង AP** : បានបញ្ចូលអាណត្តិបើកប្រាក់សម្រាប់មន្ទីរអង្គភាពជំនាញ ក្នុងប្រព័ន្ធ FMIS បូកយោង (មករា-វិច្ឆិកា) ចំនួន ១,៦១៩អាណត្តិ។
- **មុខងារការទិញ PO** : បានបញ្ចូលសំណើសុំធានាចំណាយការបញ្ជាទិញ (ស្នើសុំបើកសាច់ប្រាក់មុន) សម្រាប់មន្ទីរអង្គភាពជំនាញក្នុងប្រព័ន្ធ FMIS បានអនុវត្តបូកយោង (មករា-វិច្ឆិកា) ចំនួន៤៦គម្រោង។ បានបញ្ចូលសំណើសុំធានាចំណាយកិច្ចលទ្ធកម្មចំនួន ០០ គម្រោង បូកយោង ចំនួន ២៨៩គម្រោង។
- **មុខងារវិភាជន៍ថវិកា BA** : បានបញ្ចូលទិន្នន័យពៀកវេជ្ជទេយ្យបុរេប្រទាន បូកយោង (មករា-វិច្ឆិកា) ចំនួន ២៥ អង្គភាព។ បានបញ្ចូលនិយ័តឥណទានថវិកា សម្រាប់មន្ទីរអង្គភាពជំនាញក្នុងប្រព័ន្ធ FMIS ចំនួន០៥គម្រោង បូកយោង (មករា-វិច្ឆិកា) ចំនួន ៣១ អង្គភាព ។

**ឃ. ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ(សាលាខេត្ត ក្រុង/ ស្រុក) : (គិតត្រឹមថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២៥)**

- ពិនិត្យឯកសារ និង ចេញអាណត្តិ បូកយោងមករា-វិច្ឆិកា ចំនួន **៤៧៧**
- ធានាចំណាយក្រុង-ស្រុក បូកយោងបាន ១៩៨
- ធានាចំណាយរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត បូកយោងមករា-វិច្ឆិកា ចំនួន ០៣០
- គោលការណ៍ចំណាយរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត បូកយោងមករា-វិច្ឆិកា ចំនួន **១៧២**
- និយ័តកម្មរបស់ក្រុង-ស្រុក បូកយោងមករា-វិច្ឆិកា ចំនួន ០១៤/ និយ័តកម្មរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត បូកយោងមករា-វិច្ឆិកា ចំនួន ០០០
- បញ្ចូលប្រព័ន្ធ FMIS និងប្រគល់ការអនុម័តនូវ សំណើសុំបង្កើតវេជ្ជទេយ្យបុរេប្រទានឆ្នាំ២០២៥របស់រដ្ឋបាលខេត្តចំនួន០១,សំណើរសុំបង្កើតវេជ្ជទេយ្យបុរេប្រទានឆ្នាំ២០២៥របស់មន្ទីរពេទ្យសុខាភិបាលនៃរដ្ឋបាលខេត្តចំនួន០១ និងសំណើរសុំបង្កើតវេជ្ជទេយ្យបុរេប្រទានឆ្នាំ២០២៥របស់មន្ទីរពេទ្យបង្អែកខេត្តបូកយោងមករា-វិច្ឆិកា ចំនួន ០៣។
- តួនាទីអ្នកត្រួតពិនិត្យក្នុងប្រព័ន្ធ FMIS របស់រដ្ឋបាលខេត្ត,មុខងារៈ ការទិញ ត្រួតពិនិត្យក្នុងឆ្នាំ២០២៥ បានចំនួន៖
- ធានាចំណាយ បូកយោងមករា-វិច្ឆិកា ចំនួន ០២៩
- គោលការណ៍ចំណាយបូកយោងមករា-វិច្ឆិកា ចំនួន ០៦៣
- តួនាទីអ្នកត្រួតពិនិត្យក្នុងប្រព័ន្ធFMIS របស់រដ្ឋបាលខេត្ត,មុខងារៈគណនីត្រូវសង ត្រួតពិនិត្យក្នុង ឆ្នាំ២០២៥បានចំនួន៖បញ្ចូលអាណត្តិ បូកយោងមករា-វិច្ឆិកា ចំនួន **១៦៧**
- **សកម្មភាពការងារប្រចាំថ្ងៃរបស់ការិយាល័យ**
- ពិនិត្យឯកសារបៀវត្សប្រចាំខែ, ទូទាត់ត្រង់,ទូទាត់វេជ្ជទេយ្យបុរេប្រទាន....។ល។
- ពិនិត្យ និងចុះសំណើសុំគោលការណ៍, សំណើសុំធានាចំណាយ,សំណើសុំនិយ័តភាព,របស់រដ្ឋបាលក្រុង ស្រុក និងមន្ទីរសុខាភិបាល បញ្ចូលទៅក្នុងប្រព័ន្ធ FMIS។
- ពិនិត្យ និងចុះសំណើសុំបង្កើតវេជ្ជទេយ្យបុរេប្រទានប្រចាំឆ្នាំ ២០២៥ និងអាណត្តិរបស់មន្ទីរសុខាភិបាល បញ្ចូលទៅក្នុងប្រព័ន្ធ FMIS
- ត្រួតពិនិត្យប្រតិបត្តិការក្នុងប្រព័ន្ធ FMIS មុខងារៈគណនីត្រូវសង (ចុះអាណត្តិ) របស់រដ្ឋបាលខេត្តបាត់ដំបង
- តួនាទីអ្នកត្រួតពិនិត្យក្នុងប្រព័ន្ធ FMIS មុខងារៈការទិញ (សំណើសុំធានាចំណាយ និងសំណើសុំគោលការណ៍ចំណាយ) របស់
- រដ្ឋបាលខេត្តបាត់ដំបង

**២.៣ ការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ( គិតត្រឹមថ្ងៃទី ១៧ ខែ វិច្ឆិកា ២០២៥ )**

១.ការគ្រប់គ្រងចំណូល

ក. ចំណូលភាស៊ីគ្រប់ប្រភេទ៖ ប្រមូល បូកយោងមករា-វិច្ឆិកា ចំនួន ៤៤២,៥១២,៧៥០រៀល

ខ. ចំណូលបង្គាន់ដៃ៖ មូលបាន ៦២,៩៣៨,៤៩០ រៀលបូកយោងមករា-វិច្ឆិកា ចំនួន ២៧១,៧៩៩,២៩០រៀល

២.ការគ្រប់គ្រងបញ្ជីសារពើភណ្ឌ

ក.ការគ្រប់គ្រងបញ្ជីសារពើភណ្ឌឆ្នាំគោល ២០២៤៖

- មន្ទីរជំនាញ និងរដ្ឋបាលខេត្ត៖ ធ្វើបាន បូកយោងមករា-វិច្ឆិកា ចំនួន២៧ លើ ៣៤អង្គភាព ស្មើនឹង ៧៩%
- ក្រុង-ស្រុក៖ បានធ្វើ បូកយោង មករា-វិច្ឆិកា ចំនួន០៨ លើ១៥អង្គភាព ស្មើនឹង ៥៣%
- រដ្ឋបាលឃុំ-សង្កាត់៖ ធ្វើបានបូកយោងមករា-វិច្ឆិកា ចំនួន៥២ លើ១០៣អង្គភាព ស្មើនឹង ៥០.៤៨%

ខ.ការគ្រប់គ្រងបញ្ជីសារពើភណ្ឌឆ្នាំ ២០២៣៖ ធ្វើបាន 133លើ151អង្គភាពស្មើនឹង 88%

- មន្ទីរជំនាញ៖ ធ្វើបាន មករា-វិច្ឆិកា ចំនួន 33លើ 33អង្គភាព ស្មើនឹង 100%
- រដ្ឋបាលខេត្ត ក្រុង-ស្រុក៖ បានធ្វើមករា-វិច្ឆិកា ចំនួន 15លើ 15អង្គភាព ស្មើនឹង 100%
- រដ្ឋបាលឃុំ-សង្កាត់៖ ធ្វើបានមករា-វិច្ឆិកា ចំនួន 88 លើ 103 អង្គភាព ស្មើនឹង 85%នៅសល់ 15

គ.ការធ្វើប័ណ្ណកម្មសិទ្ធិ

- **ចំនួនដីរដ្ឋដែលបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ គិតត្រឹមថ្ងៃទី៣០ មិថុនា ២០២៥**
- ធ្វើប័ណ្ណកម្មសិទ្ធិរួចចំនួន ១៤៤២ ទីតាំង
- មិនទាន់ធ្វើប័ណ្ណកម្មសិទ្ធចំនួន ៩៥៣ ទីតាំង
- ដីបានដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិចំនួន ១៩៦ ទីតាំង
- មិនទាន់ដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិចំនួន ៦១៦ ទីតាំង
- ដីទំនាស់សរុបចំនួន ៤៤ ទីតាំង
- ដីមិនអាចធ្វើបណ្ណសរុបចំនួន ៩២ ទីតាំង
- ដីកត់ត្រាស្នូនសរុបចំនួន ៥ ទីតាំង

៣. ការគ្រប់គ្រងអាជីវកម្ម

ក. បញ្ចាំ ៖ បានចេញលិខិតអនុញ្ញាត បូកយោងមករា-វិច្ឆិកា ចំនួន ៣៣

ខ. ប្រាតិភោគ៖ បានចេញលិខិតអនុញ្ញាត បូកយោងមករា-វិច្ឆិកា ចំនួន ២៤

គ. អាជីវកម្មអភិវឌ្ឍអចលនវត្ថុ៖ បានចេញលិខិតអនុញ្ញាត បូកយោងមករា-វិច្ឆិកា ចំនួន០២ ( ០៧លិខិតអនុញ្ញាត )

៤.សកម្មភាព

- ពិនិត្យ និងទំនាក់ទំនងបញ្ជីសារពើភណ្ឌអង្គភាពមន្ទីរជំនាញ ពិសេសដោះស្រាយបញ្ហាប្រឈមក្នុងការប្រើប្រាស់ប្រព័ន្ធSARMIS ថ្មី
- ពិនិត្យ និងទំនាក់ទំនងបញ្ជីសារពើភណ្ឌ ស្រុក និងឃុំ-សង្កាត់
- ទំនាក់ទំនងការងារគ្រប់គ្រងអាជីវកម្ម
- ទំនាក់ទំនងការងារភាស៊ី

**២.៤ ការិយាល័យលទ្ធកម្មសាធារណៈ( គិតត្រឹមថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០២៥ )**

I-ការងារលើឯកសារ:

- ✧ ពិនិត្យ និង លើកយោបល់ជូនថ្នាក់ដឹកនាំចុះហត្ថលេខាលើផែនការឆ្នាំ ២០២៦ ចំនួន ០៣មន្ទីរ ដូចជា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, មន្ទីរទេសចរណ៍ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។
- ✧ ពិនិត្យ និង កែសំរួលលើផែនការឆ្នាំ២០២៦របស់រដ្ឋបាលក្រុង ស្រុក ទាំង ១៤។

II-ការងារចុះពិនិត្យជាក់ស្តែង

- ✧ ប្រគល់ទទួលការងារអនុវលទ្ធកម្ម នៅតាមបណ្តាក្រុង ស្រុកទាំង១៤។

**III-ការងារណែនាំ និង បណ្តុះបណ្តាល:** គ្មាន ។

**IV-ការងារចុះប្រព័ន្ធ:**

- ✧ ក្នុងខែវិច្ឆិកា ២០២៥ ទឹកប្រាក់សរុបនៃការអនុវត្តលទ្ធកម្មរបស់ក្រុងស្រុក ១,៥៣៤,៣៥១,៤០០ រស្មើនិង១៥គំរោង ។
- ✧ -លទ្ធកម្មទំនិញមានចំនួន៨គំរោង   តំលៃកិច្ចសន្យាសរុប        ២០៩,២៦០,០០០៛
- ✧ -លទ្ធកម្មសំណង់មានចំនួន៧គំរោង  តំលៃកិច្ចសន្យាសរុប    ១,៣២៥,០៩១,៤០០៛
- ✧ ទឹកប្រាក់សរុប១,៥៣៤,៣៥១,៤០០ ក្នុងខែវិច្ឆិកា ឆ្នាំ២០២៥ ធៀបនិងផែនការសរុប១៨,៤៧៧,៣០០,០០០៛ ឆ្នាំ២០២៥ស្មើនិង៨,៣០% ។

## ៣.បញ្ហាប្រឈម និងសំណើដំណោះស្រាយ ប្រចាំឆ្នាំ២០២៥

ទន្ទឹមនេះ  សម្រាប់ការអនុវត្តការងារប្រចាំ២០២៥មន្ទីរសេដ្ឋកិច្ច  និងហិរញ្ញវត្ថុខេត្តបាត់ដំបងបានជួបប្រទះបញ្ហាប្រឈមមួយចំនួន និងស្នើសុំជាដំណោះស្រាយដូចខាងក្រោម៖

| បញ្ហាប្រឈម | សំណើដំណោះស្រាយ |
|---|---|
| <u>១.ការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ:</u> | |
| **១.ការងារគេហទំព័រ:** ដូចជាការងាររៀបចំ "ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច និងការវិភាគ ភាពខ្លាំង, ភាពខ្សោយ,ឱកាស,និងការគំរាមគំហែង ដើម្បីកំណត់ពីសក្តានុពលនិងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍របស់ខេត្តបាត់ដំបងឆ្នាំ ២០២៥ " និងព័ត៌មានទូទៅ និងសូចនាករស្តីពី ស្ថានភាពសង្គម-សេដ្ឋកិច្ច ក្នុងខេត្តបាត់ដំបង ឆ្នាំ២០២៥ " និង "មគ្គុទេសក៏សេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត សម្រាប់ឆ្នាំ២០២៥។ ក្រុមការងារមានការពិបាកក្នុងការស្វែងរកទិន្នន័យដែលអាចទុកចិត្តបានមួយចំនួនតូចសម្រាប់ធ្វើការវិភាគ,ខ្វះខាតឧបករណ៍បច្ចេកទេស និងធនធានហិរញ្ញវត្ថុមួយចំនួន ក្នុងការពន្លឿនល្បឿន និង បង្កើនគុណភាពការងារក្នុងផ្នែកនេះ។ គេហទំព័ររបស់មន្ទីរមានភាពរអាក់រអួលញឹកញាប់។ ខ្វះមន្ត្រីបច្ចេកទេស។ ខ្វះថវិកាក្នុងការBoothហ្វេសប៊ុកផេករបស់មន្ទីរ។ទិន្នន័យដែលទទួលបានពុំទាន់មានបច្ចុប្បន្នភាព(ប្រើប្រាស់ទិន្នន័យត្រឹមឆ្នាំ២០២១)ឬមូលដ្ឋានទិន្នន័យតែមួយឆ្នាំ។ខ្វះទិន្នន័យគោលសំខាន់មួយចំនួន។ទិន្នន័យមួយចំនួនពុំអាចប្រមូលបាននៅថ្នាក់មូលដ្ឋាន និងមានតម្រូវការការសម្របសម្រួល និងផ្តល់ទិន្នន័យពីថ្នាក់ជាតិ។ ការប្រៀបធៀបទិន្នន័យរវាងខេត្ត និងខេត្តនៅមានកម្រិត។ | -ស្នើសុំទិន្នន័យបច្ចុប្បន្នភាព របស់រដ្ឋបាលខេត្ត មន្ទីរ អង្គភាព រដ្ឋបាល ក្រុង ស្រុក ដែលពាក់ព័ន្ធ ដើម្បីរៀបចំ "ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច និងការវិភាគ ភាពខ្លាំង, ភាពខ្សោយ, ឱកាស,និងការគំរាមគំហែង ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍របស់ខេត្តបាត់ដំបងឆ្នាំ ២០២៥ " និងព័ត៌មានទូទៅ និងសូចនាករស្តីពី ស្ថានភាពសង្គម-សេដ្ឋកិច្ច ក្នុងខេត្តបាត់ដំបងឆ្នាំ២០២៥ " និង "មគ្គុទេសក៏សេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត សម្រាប់ឆ្នាំ២០២៥"<br>-ស្នើសុំក្រសួងផ្តល់មន្ត្រី និងប្រាក់ថវិកាឧបត្ថម្ភលើកទឹកចិត្តដល់ក្រុមការងារគេហទំព័រច្រើននាក់បន្ថែមទៀត។<br>-ស្នើសុំកញ្ចប់ថវិកាបន្ថែម |
| **២.ការងារបណ្ណសារ:** ខ្វះមន្ត្រីបញ្ចូលប្រព័ន្ធបណ្ណសារ។ | -សូមស្នើសុំក្រសួងនូវមន្ត្រីជំនាញបណ្ណសារ និងស្នើសុំផ្តល់ថវិកាឧបត្ថម្ភលើកទឹកចិត្តដល់ក្រុមការងារបណ្ណសារ របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥។ |
| <u>២.ការិយាល័យថវិកាមន្ទីរជំនាញ:</u> គ្មាន | ➢ គ្មាន |

| | |
|---|---|
| ៣.ការិយាល័យហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ:<br>❖ ការងារចំណូល: របាយការណ៍ក្នុងប្រព័ន្ធមិនអាចទាញយកបាន ធ្វើឲ្យមិនមានតួលេខក្នុងខែ<br>❖ ការងារចំណាយ: របាយការណ៍ក្នុងប្រព័ន្ធមិនអាចទាញយកបាន ធ្វើឲ្យមិនមានតួលេខក្នុងខែ | ➢ ស្នើសុំគោលការណ៍ ឬអនុសាសន៍ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ |
| ៤.ការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ៖<br>○ អាជ្ញាធរកាន់កាប់ និងអង្គភាពប្រើប្រាស់ មិនជួយជំរុញ ការដាក់ពាក្យស្នើសុំធ្វើប័ណ្ណកម្មសិទ្ធលើដីរដ្ឋ<br>○ អង្គភាពមួយចំនួននៅមិនទាន់ធ្វើបញ្ជីសាពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋជាពិសេសរដ្ឋបាលឃុំ-សង្កាត់ | ➕ ទាមទារការសហការជាមួយសាលាខេត្ត និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សុរិយោដី និងសំណង់ ចុះទៅតាមមូលដ្ឋាន ដើម្បីជម្រុញការដាក់ពាក្យស្នើសុំធ្វើប័ណ្ណកម្មសិទ្ធលើដីរដ្ឋ<br>➕ ស្នើសុំអង្គភាពកាន់កាប់មេត្តាជំរុញការធ្វើបញ្ជីសាពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋអោយបានទាន់ពេលវេលា<br>➕ សំណូមពរ៖ ស្នើក្រសួង ស្ថាប័ន មន្ទីរជំនាញ រដ្ឋបាលខេត្ត ក្រុង-ស្រុក ឃុំ-សង្កាត់ រៀបចំគៀគរនូវទ្រព្យសម្បត្តិ ដើម្បីចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ឱ្យបានត្រឹមត្រូវ តាមបទដ្ឋានគតិយុត្តិជាធរមាន ។ |
| ៥.ការិយាល័យលទ្ធកម្មសាធារណៈ : គ្មាន | - គ្មាន |

## ៤-ទិសដៅបន្តអនុវត្តក្នុងឆ្នាំ២០២៦

| ទិសដៅបន្ត | ត្រីមាស | | | |
|---|---|---|---|---|
| | ១ | ២ | ៣ | ៤ |
| - ថ្នាក់ដឹកនាំ និងមន្ត្រីរាជការមួយចំនួនត្រៀមចូលរួមកិច្ចប្រជុំ និងកម្មវិធីនានាតាមការចាត់តាំងរបស់លោកប្រធានមន្ទីរ<br>- **បន្តស្រង់ការចូលរួមគាំទ្ររបស់មន្ត្រីរាជការប្រចាំថ្ងៃ**<br>- កំពុងរៀបចំសំណើ និងអាណត្តិទូទាត់ប្រាក់បៀវត្សប្រចាំខែ មករា-ធ្នូ ឆ្នាំ២០២៦ ជូនមន្ត្រីរាជការ និងមន្ត្រី ជាប់កិច្ចសន្យា នៃមន្ទីរ<br>- កំពុងរៀបចំអាណត្តិទូទាត់អគ្គិសនី និងថ្លៃប្រើប្រាស់ទឹក ប្រចាំខែ មករា-ធ្នូ ឆ្នាំ២០២៥ របស់មន្ទីរ<br>- កំពុងរៀបចំសំណើសុំទូទាត់បេសកកម្មជូនថ្នាក់ដឹកនាំនិងមន្ត្រីរាជការរបស់មន្ទីរសម្រាប់ត្រីមាសទី១-ទី៤<br>➢ អនុវត្តចំណូល-ចំណាយថវិកាកម្មវិធីរបស់មន្ទីរតាមកម្មវិធីត្រីមាសទី១-ទី៤ ឆ្នាំ២០២៥<br>➢ បន្តបញ្ចូលទិន្នន័យក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: ( Financial Management Information System , FMIS )<br>➢ របាយការណ៍អនុវត្តថវិកាកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាសទី១-ទី៤ឆ្នាំ២០២៦<br>➢ បន្តផុសរូបភាព និងវីដេអូសកម្មភាពរបស់ថ្នាក់ដឹកនាំ និងមន្ត្រីមន្ទីរ ក្នុងហ្វេសប៊ុកផេករបស់មន្ទីរ គេហទំព័រមន្ទីរ និងគ្រុបតេឡេក្រាមក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>➢ បន្តរៀបចំ "មគ្គុទេសក៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត សម្រាប់ឆ្នាំ២០២៦ "ប្រមូលថ្ងៃទី ៣០ ខែ សីហា ២០២៦<br>➢ បន្តរៀបចំ "ព័ត៌មានស្ថិតិសេដ្ឋកិច្ច និងសង្គមខេត្តបាត់ដំបង ឆ្នាំ២០២៦" ប្រមូលថ្ងៃទី ៣០ ខែ ក | √ | √ | √ | √ |

| | | | | |
|---|---|---|---|---|
| ញ ២០២៦<br>➢ បន្តបូកសរុបរបាយការណ៍វឌ្ឍនភាពមន្ទីរប្រចាំខែ មករា-ធ្នូ ឆ្នាំ២០២៦ និងឆ្នាំ២០២៦ សរុបជូនអគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលខេត្ត យ៉ាងយូរថ្ងៃទី ១៨ នៃខែនីមួយៗ។<br>➢ ពង្រឹងវិន័យមន្ត្រីរាជការ, ម៉ោងបំពេញការងារ និងអនុវត្តតាមការណែនាំរបស់ក្រសួង<br>➢ បណ្តុះបណ្តាលដល់មន្ត្រីកាន់មុខងារជំនួសតាមមុខសញ្ញានីមួយៗ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System , FMIS) បន្ថែមទៀត ជៀសវាងការកក់ស្ទះការងារ<br>➢ ពង្រឹងការអនុវត្តសារាចររបស់រាជរដ្ឋាភិបាលលេខ ០០៧សរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើក ផ្តល់បៀវត្សរ៍រៀងរាល់ពីរ សប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត ឲ្យបានទាន់ពេលវេលា<br>➢ ពង្រឹងការអនុវត្តឲ្យបានតាមអនុសាសន៍ណែនាំរបស់លោកប្រធានមន្ទីរ ដែលបានប្រគល់ជូនក្នុងពេលប្រជុំជីវភាពរបស់មន្ទីរ<br>➢ ពង្រឹងការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល។<br>➢ រៀបចំធ្វើបច្ចុប្បន្នភាពឯកសារ ដើម្បីរៀបចំស្នើសុំជម្រះនូវឯកសារដែលអស់សុពលភាពប្រើប្រាស់ និងឯកសារត្រូវយកទៅតម្កល់<br>-ឯកសារជានិច្ចកាល ៖ រក្សានៅអង្គភាព ០១ឆ្នាំ រួចយកទៅតម្កល់នៅក្រសួង សម្រាប់ធ្វើជម្រះនៅក្រសួង<br>-ឯកសារបណ្តោះអាសន្ន៖ រក្សានៅអង្គភាព ០១ឆ្នាំ រួចយកទៅតម្កល់នៅក្រសួង ១០ឆ្នាំ សម្រាប់ធ្វើជម្រះនៅក្រសួង<br>-ឯកសារតូចតាច ៖ ហួសសុពលភាពប្រើប្រាស់ត្រូវទុកជម្រះនៅអង្គភាពសាមី<br>-បន្តស្កេនឯកសារ និងវាយបញ្ចូលទិន្នន័យឯកសារបណ្ណសារទៅតាមប្រភេទឯកសារ ប្រចាំខែ មករា-ធ្នូ ឆ្នាំ២០២៦ ជូននាយកដ្ឋានបណ្ណសារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-បន្តរៀបចំរបាយការណ៍អវត្តមានប្រចាំខែ មករា-ធ្នូ ឆ្នាំ២០២៦ ជូននាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | | | |
| ២.**ការិយាល័យចំរិកាមន្ទីរជំនាញ:**<br>➢ ពិនិត្យ និងជំរុញបន្តទៀតនូវការអនុវត្តចំណូល-ចំណាយដើម្បីឆ្លើយតប និងកម្មវិធីត្រីមាសទី១-៤ ឆ្នាំ២០២៦<br>➢ បន្តពិនិត្យ ការទូទាត់រដ្ឋទេយ្យបុរេប្រទាន របស់មន្ទីរ អង្គភាពជំនាញឆ្នាំ២០២៦<br>➢ បន្តពិនិត្យ ការអនុវត្តធានាចំណាយតាមនីតិវិធីលទ្ធកម្មសាធារណៈរបស់មន្ទីរ អង្គភាពជំនាញ ឆ្នាំ២០២៦ | √ | √ | √ | √ |
| ៣.**ការិយាល័យហិរញ្ញវត្ថុ រដ្ឋបាលថ្នាក់ក្រោមជាតិ:**<br>➢ ពិនិត្យឯកសារ បៀវត្សរ៍ប្រចាំខែ និងឯកសារ ផ្សេងៗទៀតដូចជា (ទូទាត់រដ្ឋទេយ្យ,ទូទាត់ត្រង់,ទូទាត់លទ្ធកម្ម....) របស់រដ្ឋបាលសាលាខេត្ត, និងមន្ទីរសុខាភិបាល។<br>➢ ជំរុញអង្គភាព រដ្ឋបាលខេត្តអោយត្រៀមឯកសារស្នើរសុំឧបត្ថម្ភគុល្យភាពត្រីមាសបន្ត<br>➢ បន្តចុះសំណើសុំគោលការណ៍ ,សំណើសុំធានាចំណាយ,សំណើសុំនិយ័តភាព,និងអាណត្តិរបស់រដ្ឋបាលខេត្ត,និងមន្ទីរសុខាភិបាលចូលក្នុងប្រព័ន្ធFMIS។ | √ | √ | √ | √ |
| ៤.**ការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ:**<br>➢ បន្តការសហការជាមួយរដ្ឋបាលខេត្ត ដើម្បីជំរុញនិងបន្តការអនុវត្តការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងស្នើការអន្តរាគមន៍ដើម្បីការពន្លឿនការធ្វើបញ្ជីសារពើភណ្ឌគោល២០១៩និងតារាងប្រៀបធៀបឆ្នាំ២០១៨, ២០២១ ឆ្នាំ២០២២ និងឆ្នាំ២០២៣ | √ | √ | √ | √ |

| | | | | |
|---|---|---|---|---|
| ➢ បន្តការសហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សុរិយោដី និងសំណង់ខេត្តដើម្បីជំរុញការរៀបចំដាក់ពាក្យធ្វើប័ណ្ណកម្មសិទ្ធិដីរដ្ឋ | | | | |
| **៥.ការិយាល័យលទ្ធកម្មសាធារណៈ:**<br>➢ ពន្យល់ណែនាំអំពីនីតិវិធីលទ្ធកម្មដល់ក្រុងស្រុកទាំង១៤ | √ | √ | √ | √ |

## ៥-សំណូមពរ

- សូមស្នើសុំក្រសួងបន្តការបណ្តុះបណ្តាលផ្នែកការងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-tax Revenue Management Information System, NRMIS) , ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងបច្ចេកទេសដោះស្រាយបញ្ហាប្រឈម ក្នុងការប្រើប្រាស់ប្រព័ន្ធ SARMISជំនាន់ថ្មីបន្តទៀត ។
- សូមផ្តល់អាទិភាពដល់មន្ត្រីចាស់ៗដែលមានអតីតភាពច្រើនឆ្នាំអោយត្រូវបានតំឡើងកាំប្រាក់ដោយស្វ័យ ប្រវត្តិជាការលើកទឹកចិត្ត ។
- សូមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់យុទ្ធសាស្ត្រ ក្នុងការអនុវត្តថវិកានៅពេលដែលមានឥណទានបន្ថែម។

## ៦-សេចក្តីសន្និដ្ឋាន

ការងារទាំងឡាយ របស់អង្គភាពតាមផ្នែកនីមួយៗ បានកំពុងធ្វើសកម្មភាពយ៉ាងមមាញឹក ដើម្បីឆ្លើយតបនឹងបទបញ្ញត្តិនិងបញ្ហាប្រឈមនានា។

អាស្រ័យដូចបានជម្រាបជូនតាមរបាយការណ៍ខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងគោរពជូន ជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគោរពកិច្ចដ៏ខ្ពង់ខ្ពស់អំពី ខ្ញុំ។

ថ្ងៃ ព្រហស្បតិ៍ ០៧ កើត ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

បាត់ដំបង, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០២៥

**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង**

**ព្រំឈឹម ឆនុ**